**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

លេខ ៥៧២ សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយ និងរដ្ឋាករខេត្តត្បូងឃ្មុំ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ដែលជាអង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានការិយាល័យកណ្តាលប្រចាំនៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**ប្រការ ២.-**

សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានសាខាមួយចំនួនជាជំនួយការ។

**ប្រការ ៣.-**

សាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ មានមុខងារ និងភារកិច្ចដូចតទៅ ៖

១. គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់ លើអង្គភាពគយនិងរដ្ឋាករ ដែលស្ថិតក្រោមឱវាទ និង/ឬ ស្ថិតក្នុងភូមិសាស្ត្រខេត្តត្បូងឃ្មុំ រាប់បញ្ចូលទាំងការិយាល័យគយនិងរដ្ឋាករតាមមូលដ្ឋាន ឬតាមបណ្តាទីស្នាក់ការគយនិងរដ្ឋាករត្រួតពិនិត្យច្រកទ្វារព្រំដែននានា ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួនតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

២. ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ព័ន្ធទាំងឡាយឱ្យយល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់ នៃទំនិញនាំចូល- នាំចេញ និងការទទួលខុសត្រូវចំពោះមុខច្បាប់ រាល់ពេលរកឃើញមានការចូលរួមគេចវេសកាតព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬដោយប្រយោល ការធ្វើចរាចរ ចែកចាយ សន្និធិទំនិញនាំចូល- នាំចេញដោយល្មើសនានាក្នុងមូលដ្ឋានអាជីវកម្មដ្ឋាន ឬលំនៅដ្ឋាននីមួយៗ។

៣. ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់ខេត្តត្បូងឃ្មុំលើទំនិញនាំចូល- នាំចេញដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬកំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា និងទទួលខុសត្រូវនូវនិរន្តរភាពចំណូលពន្ធអាករគយ ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន។

៤. ចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិអាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានាដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលតេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀត ដែលនឹងកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៥. សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសម្រេចឱ្យបាននូវភារកិច្ចដូចបានចែងក្នុងប្រការនេះ។

៦. អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្របតាមបទបញ្ញត្តិច្បាប់ជាធរមាន។

**ប្រការ ៤.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- គ្រប់សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ